ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

EAC

អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ ៤៨៨ សា.១៧ អអក

ភ្នំពេញ, ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៧

## សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

## ស្តីពីការពិគ្រោះយោបល់សាធារណៈក្នុងការកែសម្រួលអាជ្ញាបណ្ណរបស់ក្រុមហ៊ុន អូ អេស វី អ ត្រេឌីង សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកទឹកផុស និងស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង

អាជ្ញាធរអគ្គិសនីកម្ពុជាមានកិត្តិយសសូមជម្រាបជូនសាធារណជននៅក្នុងស្រុករលាប្អៀរ និងឃុំក្រាំងស្គារ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ឲ្យបានជ្រាបថា អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណរបស់ក្រុមហ៊ុន អូ អេស វី អ ត្រេឌីង ដើម្បីអនុញ្ញាតឲ្យដកតំបន់ចែកចាយអគ្គិសនីមួយផ្នែកនៃស្រុករលាប្អៀរ និងឃុំក្រាំងស្គារ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ពីតំបន់ចែកចាយដែលមានស្រាប់តាមខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណ ដូចមានជូនភ្ជាប់មកជាមួយនេះ ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការកែសម្រួលអាជ្ញាបណ្ណ អាជ្ញាធរមូលដ្ឋាន ស្ថាប័ននានាដែលពាក់ព័ន្ធ និងសាធារណជនមានសិទ្ធិពិនិត្យ ផ្តល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា លើខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណ ដែលគ្រោងផ្តល់ជូនក្រុមហ៊ុន អូ អេស វី អ ត្រេឌីង ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណនៅ----------------------------------------------------------------------------------------------------------សម្រាប់សាធារណជនពិនិត្យ ។

អាស្រ័យហេតុនេះ សូមសាធារណជននៅក្នុងស្រុករលាប្អៀរ និងឃុំក្រាំងស្គារ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្តល់យោបល់លើខ្លឹមសារនៃការចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណ ក្រុមហ៊ុន អូ អេស វី អ ត្រេឌីង អាចអញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្តល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះ រហូតដល់ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៧ ។ អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា **"អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណា ដែលមានបង្ហាញនូវហេតុផលយ៉ាងច្បាស់លាស់ប៉ុណ្ណោះ"**

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**សមាជិកទី១**

**យឹម វិសិដ្ឋ**

**សេចក្តីព្រាង**

EAC

# អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA

## ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
ELECTRICITY LAW OF THE KINGDOM OF CAMBODIA

# សេចក្តីសម្រេចកែសម្រួលលើកទី៥

## លើឯកសារអាជ្ញាបណ្ណលេខ ៣០០ ឯអ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១០ សម្រាប់ក្រុមហ៊ុន អូ អេស វី អ ត្រេឌីង ធ្វើសេវាកម្មអគ្គិសនី នៅផ្នែកខ្លះនៃស្រុកទឹកផុស និងស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង

## សម្រាប់ការដកតំបន់ចែកចាយ

# DECISION ON THE FIFTH REVISION

OF THE LICENSE DOCUMENT No.300 LD DATED OCTOBER 27, 2010 OF O S V R TRADING CO., LTD FOR PROVIDING ELECTRIC POWER SERVICES AT SOME PARTS OF TEUKPHOS AND ROLEAR PHEAR DISTRICTS, KAMPONG CHHNAING PROVINCE

## FOR WITHDRAWING DISTRIBUTION AREA

ថ្ងៃទី      ខែ      ឆ្នាំ២០១៧

.. .., 2017

**ព្រះរាជាណាចក្រកម្ពុជា**

KINGDOM OF CAMBODIA

**ជាតិ សាសនា ព្រះមហាក្សត្រ**

NATION RELIGION KING

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

ELECTRICITY AUTHORITY OF CAMBODIA

លេខ ៖ -១៧-អអក

# សេចក្ដីសម្រេចកែសម្រួលលើកទី៥ លើឯកសារអាជ្ញាបណ្ណលេខ ៣០០ ឯអ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១០ សម្រាប់ក្រុមហ៊ុន អូ អេស វី អ ត្រេឌីង

# DECISION ON THE FIFTH REVISION OF THE LICENSE DOCUMENT No.300 LD DATED OCTOBER 27, 2010 FOR O S V R TRADING CO., LTD

## អាជ្ញាធរអគ្គិសនីកម្ពុជា

## ELECTRICITY AUTHORITY OF CAMBODIA

- អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្ដីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យដោយ ព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

-In exercise of the powers conferred by Article 7 and 35 of the Electricity Law promulgated by the Royal Decree No. NS/RKM/0201/03 dated 2 February 2001.

-យោងឯកសារអាជ្ញាបណ្ណលេខ ៣០០ ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញឲ្យក្រុមហ៊ុន អូ អេស វី អ ត្រេឌីង នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១០

-Refer to the License Document No.300 LD issued by Electricity Authority of Cambodia to OSVR Trading Co., Ltd on October 27, 2010.

-យោងលិខិតស្នើសុំដកតំបន់ចែកចាយរបស់ក្រុមហ៊ុន អូ អេស វី អ ត្រេឌីង ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧

- Refer to the requested letter of O S V R Trading Co., Ltd for withdrawing distribution area, dated May 15, 2017.

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី ខែ ឆ្នាំ ២០១៧ ដល់ថ្ងៃទី ខែ ឆ្នាំ ២០១៧

- In accordance with the consultation with concerned parties and public, made from , 2017 to , 2017.

-យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី ចុះថ្ងៃទី ខែ ឆ្នាំ ២០១៧

- In accordance with the decision of Electricity Authority of Cambodia's Session No. , dated , 2017.

## សម្រេច
## DECIDES

| | |
|---|---|
| **ប្រការ១**<br>កែសម្រួលឯកសារអាជ្ញាបណ្ណលេខ ៣០០ ឯអ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ ២០១០ ដែលបានផ្តល់ជូនក្រុមហ៊ុន **អូ អេស វី អ ត្រេឌីង** (បន្ទាប់ពីនេះហៅថា " **អ្នកកាន់អាជ្ញាបណ្ណ** " ) សម្រាប់ធ្វើសេវាកម្មអគ្គិសនីក្នុងតំបន់អនុញ្ញាតដែលកំណត់ក្នុងឧបសម្ព័ន្ធទី១ ដើម្បីផ្តល់សិទ្ធឲ្យអ្នកកាន់អាជ្ញាបណ្ណដូចខាងក្រោម:<br>-អនុញ្ញាតឲ្យអ្នកកាន់អាជ្ញាបណ្ណ ដកតំបន់ចែកចាយអគ្គិសនីមួយផ្នែកនៃឃុំក្រាំងលាវ និងឃុំបន្ទាយព្រាល ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ចេញពីតំបន់ចែកចាយរបស់ខ្លួនឲ្យទៅក្រុមហ៊ុន អ៊ុង សុវណ្ណនី អេឡិកទ្រីស៊ីធី ឌីវេឡុបមេន កាន់អាជ្ញាបណ្ណលេខ ០៥១ អ ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ ២០០៣ ធ្វើសេវាកម្មអគ្គិសនីជំនួសវិញ មានបង្ហាញក្នុងផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធទី២ កែសម្រួលថ្មី ។<br>-អនុញ្ញាតឲ្យអ្នកកាន់អាជ្ញាបណ្ណ ដកតំបន់ចែកចាយអគ្គិសនីមួយផ្នែកនៃឃុំក្រាំងស្គារ ស្រុកទឹកផុស និងឃុំប្រស្និប ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ចេញពីតំបន់ចែកចាយរបស់ខ្លួនឲ្យទៅលោកស្រី អេន ចន្ថា កាន់អាជ្ញាបណ្ណលេខ ៤២៩ អ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១៧ ធ្វើសេវាកម្មអគ្គិសនីជំនួសវិញ មានបង្ហាញក្នុងផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធទី២ កែសម្រួលថ្មី ។ | **Article 1**<br>To revise the license document No.300 LD dated October 27, 2010 issued to **OSVR Trading Co., Ltd** (herein after referred to as "**Licensee**") to supply the electric power service in authorized distribution areas is determined in schedule 1 :<br>- To allow to licensee to withdraw a part of Khum Kraing Leav and Khum Bonteay Preal, Rolear Phear District, Kampong Chhnaing Province from existing distribution area and transfer the management to Oung Sovanny Electricity Development Co., Ltd, hold the license No.051 LD dated September 09, 2003 as shown in the attached map in new revised schedule 2.<br>- To allow to licensee to withdraw a part of Khum Kraing Skar, Tekphos District and Khum Bro Sneb, Rolear Phear District, Kampong Chhnaing Province from existing distribution area and transfer the management to Mrs. En Chantha, hold the license No.429 LD dated April 11, 2017 as shown in the attached map in new revised schedule 2 |
| **ប្រការ២**<br>ឧបសម្ព័ន្ធទី២ចាស់ នៃឯកសារអាជ្ញាបណ្ណលេខ ៣០០ ឯអ ត្រូវជំនួសដោយឧបសម្ព័ន្ធទី២ កែសម្រួលថ្មីដែលមានភ្ជាប់មកជាមួយ ។ | **Article 2**<br>The existing schedule 2 of the license document No. 300 LD is replaced by the new revised schedule 2 attached herewith. |
| **ប្រការ៣**<br>ខ្លឹមសារ និងលក្ខខណ្ឌដទៃទៀតនៃឯកសារអាជ្ញាបណ្ណលេខ ៣០០ ឯអ ត្រូវស្ថិតនៅជាធរមានដដែល ។ | **Article3**<br>The other contents and conditions of the license document No. 300 LD shall remain unaltered and in force |
| **ប្រការ៤**<br>សេចក្តីសម្រេចនេះ ត្រូវចាត់ទុកជាផ្នែកមួយនៃឯកសារអាជ្ញាបណ្ណលេខ ៣០០ ឯអ ។ | **Article 4**<br>This decision shall be considered as a part of license document No. 300 LD. |
| **ប្រការ៥**<br>សេចក្តីសម្រេចនេះ ត្រូវចូលជាធរមានចាប់ពីថ្ងៃបើកសម័យប្រជុំលើកទី.. តទៅ។ | **Article 5**<br>This decision shall come into force from the date of session No.. |
| **ប្រការ៦**<br>អ្នកកាន់អាជ្ញាបណ្ណ ត្រូវធ្វើសេចក្តីសម្រេចនេះ ទៅតម្កល់ទុកបន្ថែមនៅតាមទីកន្លែងដែលឯកសារអាជ្ញាបណ្ណលេខ ៣០០ ឯអ បានតម្កល់ទុកពីមុន ដើម្បីឲ្យឯកសារអាជ្ញាបណ្ណលេខ ៣០០ ឯអ ដែលតម្កល់ទុកមានការកែសម្រួលជាថ្មីស្របតាមសេចក្តីសម្រេចនេះ ។ | **Article 6**<br>The licensee shall send this decision to deposit additionally at the places, where the license document No. 300 LD has been deposited in order that the deposited license document No. 300 LD is in conformity with this decision. |

ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០១៧

Phnom Penh, , 2017

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

CHAIRMAN OF ELECTRICITY AUTHORITY OF CAMBODIA